**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

# របាយការណ៍សកម្មភាពស្តីពីការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

## រយៈពេល ៤ថ្ងៃ៖ ថ្ងៃទី ២៥ ដល់ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២៣

ដោយទទួលបានការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ូយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានការដឹកនាំដោយផ្ទាល់ដោយ **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងរយៈពេល ៤ថ្ងៃ គឺចាប់ពីថ្ងៃទី ថ្ងៃទី ២៥ ដល់ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ នៃយុទ្ធនាការនេះមានការរៀបចំដោយក្រុមការងារមជ្ឈមណ្ឌលជាតិ និងអង្គការដៃគូពាក់ព័ន្ធបានធ្វើការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍និងជំងឺអេដស៍ និងចុះចែកស្រោមអនាម័យដោយឥតគិតថ្លៃ ដល់កីឡាករអុំទូក និងដល់សាធារណជនដែលចូលរួមនៅក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ទៅតាមទីតាំងស្តង់ចំនួន ២កន្លែង ផ្សេងគ្នាទី(១) នៅទីធ្លាក្រុងរណបជ្រោយចង្វារ OCIC ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ រៀបចំដោយក្រសួងសុខាភិបាលមជ្ឈមណ្ឌល



ជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ សហការជាមួយអង្គការដៃគូរួមមាន KHANA, MHC, CWPD & AHF និង ទី(២)នៅរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំចាប់ពី ថ្ងៃទី ២៦ ដល់ ថ្ងៃទី ២៨ ឆ្នាំ២០២៣ ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សហការជាមួយក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អង្គការដៃគូ KHANA, AHF, MHC, CWPD & RHAC ។

ជាផែនការតាមការគ្រោងទុកក្រុមការងារក្រុមការងារមជ្ឈមណ្ឌលជាតិ និងក្រុមអង្គការដៃគូពាក់ព័ន្ធបានត្រៀមទុកនូវកម្លាំងសម្រាប់ចុះអនុវត្តយុទ្ធនាការ សម្ភារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពនៃការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នេះនូវស្រោមអនាម័យ ចំនួន ១០០,០០០ ស្រោម ទឹករំអិល ចំនួន ៣០,០០០ កញ្ចប់ ខិត្តប័ណ្ណផ្សព្វផ្សាយអំពីការការពារ និងធ្វើតេស្ត ឈាមចំនួន ២០,០០០ សន្លឹក ខិត្តប័ណ្ណស្តីពី PrEP ចំនួន ២០,០០០ សន្លឹក អាវយឺត ចំនួន ១,០០០ អាវ និងខិត្តប័ណ្ណអប់រំផ្សេងៗមួយចំនួនប្រមាណចំនួន២០,០០០ សន្លឹក ទៀត ។

- **សមាសភាពក្រុមការងារចាប់ពីថ្ងៃទី ២៥ ដល ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២៣**
  - មន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
  - មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ៣៥ រូប
  - ក្រុមការងារ KHANA ០៤ រូប (ប្រធានកម្មវិធី ០១ រូប និងបុគ្គលិក ០៣ រូប)
  - ក្រុមការងារ FHI360 (Epic) ០៤ រូប
  - ក្រុមការងារ MHC ១៤ រូប (មន្ត្រីកម្មវិធី ០២ រូប និងបុគ្គលិក ១២ រូប)
  - ក្រុមការងារ CWPD ១៧ រូប (មន្ត្រីកម្មវិធី ០១ រូប និងបុគ្គលិក ១៦ រូប)
  - ក្រុមការងារ AHF ១៥ រូប (OW ១០ រូប)
  - ក្រុមការងារ WNU ១៥ រូប
  - ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប

- **សកម្មភាព៖**




សម្រាប់ទាំង ៤ថ្ងៃ នៃយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នៃពិធីបុណ្យអុំទូក បណ្តែត ប្រទីប និងសំពះព្រះខែ អកអំបុកបានបន្តយ៉ាងរលូនដោយមានការចូលរួមដោយមន្ត្រីជំនាញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយសហការណ៍ជាមួយអង្គកាដៃគូពាក់ព័ន្ធរួមមាន(KHANA, FHI360, MHC, CWPD, AHF WNU) នៅទីតាំងទីក្រុងរណបជ្រោយចង្វារ(OCIC) ដែលជាកន្លែងកីឡា និងទីតាំងរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំគឺជាកន្លែងកីឡាករដើរលេងកំសាន្ត ជាពិសេសពេលរាត្រីដោយក្រុមការងារបានធ្វើការ



បែងចែកជាក្រុមចល័តសម្រាប់ចុះផ្សព្វផ្សាយអប់រំដោយផ្ទាល់ដល់កីឡាករអុំទូក និងប្រជាពលរដ្ឋទូទៅស្ដីពីការបង្ការការចម្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ការចែកជូនអាវយឺត ចែកទឹករំអិល និងស្រោមអនាម័យតាមទីតាំងនីមួយៗដោយឥតគិតថ្លៃ។ លើសពីនេះទៅទៀតក្រុមការងារបានមានមតិសំណេះសំណាល និងបានធ្វើការអប់រំផ្សព្វផ្សាយជុំវិញមេរោគអេដស៍ជំងឺអេដស៍ និងការបង្ការផ្សេងៗដោយក្រុមការងារទៅកាន់បងប្អូនជាកីឡាករទូកង




ប្រមាណជាង ៣០០ នាក់ ដែលកំពុងមានវត្តមាននៅស្តង់ជិតនោះដោយមានការសម្របសម្រួលពិសេសជាមួយប្រធានក្រុមរបស់កីឡាករទូកងក្នុងការបញ្ជ្រាបការយល់ដឹងស្ដីពីការបង្ការមេរោគអេដស៍និងជំងឺអេដស៍។ ក្នុងនោះផងដែរក្រុមការងារបានធ្វើបទសម្ភាសន៍ជាមួយវិទ្យុបារាំងអន្តជាតិ( RFI ) ស្ថានីយ៍ទូរទស្សន៍អប្សរា និងក្រុមសារព័ត៌មានបានចុះយកព័ត៌មាន និងចុះផ្សាយនូវសកម្មភាពនៃយុទ្ធនាការនេះផង ដែលដើម្បីចូលរួមចំណែកបន្ថែមក្នុងការពង្រីកការផ្សព្វផ្សាយខ្លឹមសារអប់រំក្នុងអំឡុងព្រឹត្តិការណ៍នេះ។

យុទ្ធនាការនោះផងដែលក៏មានការចូលរួម បិទ និង បើកក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការ** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមានការរៀបចំការប្រគុំតន្ត្រីដែលត្រូវបានរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង



អង្គការដៃគូដើម្បីពង្រីកសារនៃការអប់រំទាំងនេះពេលរាត្រី និងបញ្ជ្រាបការយល់ដឹងស្ដីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជាស់តឿនក្រើនរំឭកដល់កីឡាករអុំទូក និងបងប្អូនជនរួមជាតិទាំងអស់ សូមឱ្យប្រុងប្រយ័ត្នបង្ការខ្លួនជាប់ជានិច្ចកុំឱ្យឆ្លងមេរោគអេដស៍ព្រោះជំងឺអេដស៍ និងសុំឱ្យប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% នៅពេលមានដៃគូក្រៅ និងប្រញាប់ទៅ

ធ្វើតេស្តឈាមរកមេរោគអេដស៍ប្រសិនបើសង្ស័យថាមានផ្ទុកមេរោគអេដស៍ ដើម្បីឆាប់បានទៅទទួលសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាម និងទទួលឱសថពន្យារជីវិតអោយបានកាន់តែឆាប់រហ័សក្នុងថ្ងៃតែមួយ។

- **សមិទ្ធផលសង្ខេបរួមទាំងពីរទីតាំងចាប់ពីថ្ងៃទី ២៥ ដល់ ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២៣ ៖**

| ល.រ | សកម្មភាពទាំង ២ទីតាំង | ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | ២,៥៤៦ នាក់ | ៥,១១៣ នាក់ | ៤,៩៩៥ នាក់ | ៣,៩៧៤ នាក់ | សរុប ៤ថ្ងៃ (១៦,៦២៨ នាក់) |
| ២ | បានធ្វើតេស្តឈាម | ១៣ នាក់ | ៤៣ នាក់ | ៣៦ នាក់ | ៤៦ នាក់ | សរុប ៤ថ្ងៃ (១៣៨ នាក់) |
| ៣ | លទ្ធផលអេដស៍តេស្តប្រតិកម្ម | ០ នាក់ | **២ នាក់** | **២ នាក់** | **០ នាក់** | ៤ នាក់ |
| ៤ | លទ្ធផលស្វាយតេស្តប្រតិកម្ម | ០ នាក់ | **២ នាក់** | **១ នាក់** | **១ នាក់** | ៤ នាក់ |
| ៥ | បានចែកស្រោមអនាម័យ | ១២,៩៨៤ ស្រោម | ២៩,៤៨៧ ស្រោម | ១៣,១៥១ ស្រោម | ១៤,១៥៦ ស្រោម | សរុប ៤ថ្ងៃ (៦៩,៧៧៨ ស្រោម) |
| ៦ | បានចែកទឹករំអិល | ៤,៥៥៨ កញ្ចប់ | ៧,០៣៤ កញ្ចប់ | ២,១៨៦ កញ្ចប់ | ១,៤១៦ កញ្ចប់ | សរុប ៤ថ្ងៃ (១៥,១៩៤ កញ្ចប់) |
| ៧ | បានចែកខិត្តប័ណ្ណ | ២,៦៨៧ សន្លឹក | ៥,២៦៩ សន្លឹក | ៦,២០៣ សន្លឹក | ៤,៤៥២ សន្លឹក | សរុប ៤ថ្ងៃ (១៨,៦១១ សន្លឹក) |
| ៨ | បានចុះឈ្មោះសេវា PrEP | ០ នាក់ | ១ នាក់ | ០ នាក់ | ០ នាក់ | ទទួលសេវានៅមណ្ឌលសុខភាព ទួលគោក |
| ៩ | អាវយឺតសម្រាប់អប់រំ | ២៥០ អាវ | ៤០០ អាវ | ១៥០ អាវ | ២០០ អាវ | |

ថ្ងៃពុធ ០២រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០២៣

បានឃើញ និងឯកភាព

សាស្ត្រាចារ្យ ជ.អ៊ុក វិជ្ជា

បានពិនិត្យត្រឹមត្រូវ

វេជ្ជបណ្ឌិត ង៉ូវ បូរ៉ា

ធ្វើសេចក្តីរាយការណ៍ដោយ

លោក ចំរើន បូរ៉ា